# SD USD San Diego Unified School District Fact Sheet

## មាតាបិតាសាកលវិទ្យាល័យប្រចាំ សាន់ឌីអេហ្គោ

តាមការសិក្សាស្រាវជ្រាវសំខាន់ៗបង្ហាញថា ពេលមាតាបិតាចូលរួមជាសកម្មជាមួយការសិក្សារបស់កូននោះអាចធ្វើអោយការសិក្សារបស់កូនមានការល្អតលាស់។ មាតាបិតាសាកលវិទ្យាល័យប្រចាំ សាន់ឌីអេហ្គោ បានរៀបចំបង្កើតឡើងនៅក្នុងខែ តុលា ឆ្នាំ ២០០០។ ក្រុមនេះធ្វើឡើងដើម្បីជួយមាតាបិតាឲ្យមានចំណូលចិត្តចូលរួមជាមួយការសិក្សារបស់កូនដូចជា: ធ្វើជាគ្រូជួយបង្រៀនដល់កូនសិក្សា, ពង្រឹងជំនាញការណែនាំកូន, ព្រមទាំងពង្រឹងទំនាក់ទំនងរវាងមាតាបិតា-និងកូនឲ្យឲ្យកាន់តែខ្លាំងឡើងៗ។ មាតាបិតាសាកលវិទ្យាល័យមានប្រចាំការដើម្បីជួយដល់មាតាបិតាសិស្សរៀននៅក្នុងសាលារៀនដែលមានកម្មវិធី Title I និងសាលារៀនដែលមានសិស្សភាគច្រើនរៀនបានអន់ខ្សោយ។

> **សង្ខេប**
>
> - ការចូលរួមសិក្សាហ្វឹកហ្វឺនផ្តល់ឲ្យមាតាបិតាដែលមានកូនរៀនចាប់ពីថ្នាក់ បុរេផ្ការ ដល់ ថ្នាក់វិទ្យាល័យ ចាប់ពីខែ កញ្ញា ដល់ ខែ កក្កដា ។
> - ថ្នាក់ណែនាំមាតាបិតាបង្រៀនចាប់ពីម៉ោង ៩:៣០ ដល់ ១១:៣០ព្រឹក ថ្ងៃ ចន្ទ - ព្រហស្បតិ៍ ។ កាលវិភាគចូលរួមសិក្សាមានការខុសៗគ្នា
> - ការដឹកជញ្ជូនដោយឥតគិតថ្លៃឈ្នួល
> - មានកម្មវិធីជួយថែរក្សាក្មេងចាប់ពីអាយុ ០ ដល់ ៥ឆ្នាំ
> - ក្រុមសហគមន៍ដែលជាដៃគូផ្តល់រង្វាន់លើកទឹកចិត្តដល់មាតាបិតាដែលចូលរួមរាល់ថ្ងៃ។
> - មានឯកសារផ្តល់ជូនសំរាប់មាតាបិតាដែលត្រូវការកម្មវបញ្ហារឡើងដោយគុណាការ។

ថ្នាក់បង្រៀននៅតាមមជ្ឈមណ្ឌលមាតាបិតាប្រចាំ Harold J. Ballard ស្ថិតនៅ 2375 Congress Street នៅ Old Town (ពីមុនជាសាលាបឋមសិក្សា Fremont)។ ថ្នាក់សិក្សាជួយផ្តល់ដល់មាតាបិតានូវជំនាញការប្រុងប្រៀបខ្លួនចូលរៀន, ជំនាញការសិក្សា, និងភាសា, បណ្តុះបណ្តាលអក្សរសាស្ត្រ និងគណិតសាស្ត្រ ដើម្បីជួយគាំទ្រសិស្សសិក្សាពីថ្នាក់មត្តេយ្យដ្ឋានដល់សិស្សសាលាវិទ្យាល័យ។ នៅក្នុងថ្នាក់អប់រំ មាតាបិតាអាចទទួលការសិក្សាដើម្បីជួយកូនចូលរួមជាមួយសង្គម, ដោះស្រាយបញ្ហាកូន, និងបីបាច់រក្សាកូនដោយមានការប្រស្រ័យទាក់ទាក់ទងកូនឲ្យបានជិតស្និត។ ថ្នាក់ដឹកនាំអាចជួយដល់មាតាបិតាចូលរួមជាដៃគូជាមួយបុគ្គលិកសាលារៀន។

ថ្នាក់បង្រៀននៅពេលថ្ងៃផ្តល់អោយចាប់ពីថ្ងៃ ចន្ទ ដល់ ព្រហស្បតិ៍ ចាប់ពីម៉ោង ៩:៣០ ដល់ ១១:៣០ព្រឹក។ ថ្នាក់បង្រៀនទាំងនេះចាត់ចែងបង្រៀនដោយលោកគ្រូ-អ្នកគ្រូ, គ្រូផ្តល់ឱវាទមានសញ្ញាប័ត្រ ព្រមទាំងសមាជិកសហគមន៍មានជំនាញការបង្រៀន អង់គ្លេស និងស្ពេនីសទីគ្រប់គ្រាន់។ យើងមានរថយន្តសំរាប់ដឹកជំញូនមាតាបិតាជ្រើសរើសចូលរួមសិក្សានៅតាមសាលារៀនក្នុងក្រសួងអប់រំប្រចាំក្រុងដោយឥតគិតថ្លៃឈ្នួល។

បន្ថែម សម្ភារៈសិក្សាសំរាប់មាតាបិតាធ្វើយកទៅអោយកូន/មន្ទីសិក្សា ផ្តល់ដល់មាតាបិតាមានជំនាញការសិក្សាផ្ទាល់ដៃដោយរៀបចំល្បែងកំសាន្តសំរាប់កូនសិក្សាផ្នែករៀនអាន និងគណិតសាស្ត្រ, ព្រមទាំងជំនួយសិក្សាដើម្បីគាំទ្រការបណ្តុះបណ្តាលការសិក្សាសកូនអោយបានសប្បាយរីករាយ, បង្កើតកម្មវិធីសិក្សាជាមួយសមាជិកទាំងអស់ក្នុងគ្រួសារ។ មាតាបិតា និងលោកគ្រូ-អ្នកគ្រូអាចអញ្ជើញមកចូលរួមជាមួយក្នុងបន្ទប់មន្ទីពិសោធន៍ ពេលម៉ោងសិក្សាបាន។ មន្ទីពិសោធន៍ផ្តល់កម្មវិធីសិក្សាផ្ទាល់ដល់មាតាបិតាធ្វើសម្ភារៈសំរាប់កូនប្រើប្រាស់សិក្សានៅតាមផ្ទះ និងប្រើប្រាស់កុំព្យូទ័រជាមួយប្រព័ន Internet។ សាលារៀនអាចរៀបចំកាលវិភាគសំរាប់ក្រុមមាតាបិតាដែលមានគ្នាយ៉ាងហោចណាស់ចំនួន ២០នាក់ ចូលរួមអញ្ជើញទៅមជ្ឈមណ្ឌលមាតាបិតា Ballard បាន។ ពេលមាតាបិតាចូលជាមួយក្រុមមាតាបិតានេះ យើងមានបុគ្គលិកជួយមើលកូនអោយ ព្រមទាំងមានរថយន្តសំរាប់ដឹកជញ្ជូនមាតាបិតាសិស្សមកចូលរួមប្រជុំសិក្សាផងដែរ។

ពេលមាតាបិតាចូលរួមជាមួយកម្មវិធីសិក្សានេះ កូនរបស់គាត់ដែលរៀននៅថ្នាក់បុរេផ្គានទឹងចូលរួមជាមួយមជ្ឈមណ្ឌលកម្មវិធីណែនាំសិស្សប្រុងប្រៀបសិក្សាដែលជាកម្មវិធីបណ្តុះបណ្តាលថែរក្សាក្មេង។ មជ្ឈមណ្ឌលកម្មវិធីណែនាំសិស្សប្រុងប្រៀបខ្លួនសិក្សាផ្តល់ការបំរើសិស្សចាប់ពីអាយុកើតដល់៥ប្រាំដែលមិនទាន់ចូលរៀនសាលាជាផ្លូវការណ៏នៅតាមតំបន់សាលារៀន ឬសហគមន៍របស់ខ្លួន។ សិស្សបុរេផ្គានចូលរួមជាមួយកម្មវិធីជាច្រើនដើម្បីសិក្សាពង្រឹងផ្នែក ភាសា, រៀនអានសៀវភៅអោយបានទាន់ពេល ព្រមទាំងជំនាញការបណ្តុះបណ្តាលផ្នែកសង្គម។

- បន្ត -



San Diego Parent University. Cambodian.

# SD USD San Diego Unified School District Fact Sheet

សហគមន៍ជាដៃគូទទួលគម្រោងថវិការជារង្វាន់ដើម្បីលើកទឹកចិត្តដល់មាតាបិតាដែលបានចូលរួម។ រង្វាន់មានរួមដូចជា: សៀវភៅសំរាប់សិស្សបន្ថែមនៅតាមបណ្ណាល័យរបស់ខ្លួននៅតាមផ្ទះ ព្រមទាំងសញ្ញាប័ត្រដែលជារង្វាន់សំរាប់មាតាបិតាចូលរួមជាមួយកម្មវិធីនេះ។